ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស
នាយកដ្ឋានកិច្ចការអាស៊ាន
លេខ: ០១/២០២២

# សេចក្ដីជូនព័ត៌មាន

------------

នាយកដ្ឋានកិច្ចការអាស៊ាន នៃអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ នឹងរៀបចំកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន (ADSOM WG) និងកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ានបូក (ADSOM-Plus WG) ដែលនឹងប្រព្រឹត្តទៅជាបន្តបន្ទាប់គ្នា ពីថ្ងៃ០៧ ដល់០៩ ខែកុម្ភៈ ឆ្នាំ២០២២ នៅអគាររដ្ឋបាល ទីស្ដីការក្រសួងការពារជាតិ រាជធានីភ្នំពេញ។ កិច្ចប្រជុំទាំងពីរនេះនឹងដឹកនាំដោយ**ឯកឧត្តម ឧត្តមសេនីយ៍ឯក ឡៃ ចិន្តា** អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស និងជាប្រធានក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ានរបស់កម្ពុជា ដោយមានការចូលរួមពីសំណាក់ប្រធានក្រុមការងារឧត្តមមន្ត្រីការពារជាតិនៃរដ្ឋជាសមាជិកអាស៊ាន ប្រធានក្រុមការងារឧត្តមមន្ត្រីការពារជាតិនៃបណ្ដាប្រទេសបូក មជ្ឈមណ្ឌលវេជ្ជសាស្ត្រយោធាអាស៊ាន រួមទាំងតំណាងអគ្គលេខាធិការដ្ឋានអាស៊ាន ទទួលបន្ទុកសហគមន៍នយោបាយសន្តិសុខអាស៊ាន។

នៅក្នុងកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន បណ្ដាប្រទេសជាសមាជិកអាស៊ាននឹងធ្វើបច្ចុប្បន្នភាពលើដំណើរការនៃកិច្ចសហប្រតិបត្តិការការពារជាតិអាស៊ានដែលមានស្រាប់ក្នុងក្របខ័ណ្ឌកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន។ ជាមួយគ្នានេះអង្គប្រជុំក៏ និងធ្វើការពិភាក្សា និងពិនិត្យពិចារណាលើឯកសារយុទ្ធសាស្ត្រនៃគំនិតផ្ដួចផ្ដើមថ្មីៗ ក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM) ក្នុងគោលដៅពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាក់ស្ដែង។ ឯកសារសំខាន់ចំនួន ២ រួមមាន៖ សេចក្ដីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន និងសេចក្ដីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក ក៏ត្រូវបានដាក់យកមកពិភាក្សាផងដែរ។ ជាមួយគ្នានោះដែរ បណ្ដាអ្នកចូលរួម ក៏នឹងពិភាក្សាផងដែរអំពីជំងឺកូវីដ១៩ ដោយផ្ដោតជាសំខាន់លើចក្ខុវិស័យស្ដីពីតួនាទីនៃស្ថាប័នការពារជាតិ ដើម្បីគាំទ្រការស្ដារឡើងវិញក្រោយកូវីដ១៩។

ដោយឡែក នៅក្នុងកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន-បូក បណ្ដាប្រទេសជាសមាជិកនឹងស្ដាប់សេចក្ដីរាយការណ៍ និងផែនការបន្តរបស់សហប្រធានក្រុមការងារជំនាញទាំង៧ វិស័យក្នុងក្របខ័ណ្ឌកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក ក្នុងនោះរួមមាន ១) ជំនួយមនុស្សធម៌ និងសង្គ្រោះ

គ្រោះមហន្តរាយ ២) សន្តិសុខលម្ហសមុទ្រ ៣) វេជ្ជសាស្ត្រយោធា ៤) ប្រឆាំងភេរវកម្ម ៥) ប្រតិបត្តិការរក្សាសន្តិភាព ៦) សកម្មភាពកំចាត់មីនដើម្បីមនុស្សធម៌ និង៧) សន្តិសុខបច្ចេកវិទ្យាព័ត៌មាន។

កិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ាន និងកិច្ចប្រជុំក្រុមការងារឧត្តមមន្ត្រីការពារជាតិអាស៊ានបូក ឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងនាមជាម្ចាស់ផ្ទះនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន និងកិច្ចប្រជុំសន្តិសុខពាក់ព័ន្ធក្នុងឆ្នាំ២០២២ ក្នុងការបន្តជំរុញកិច្ចសហប្រតិបត្តិការការពារជាតិក្នុងតំបន់ដើម្បីដោះស្រាយបញ្ហាប្រឈមរួមក្នុងពេលបច្ចុប្បន្ន និងបញ្ហាប្រឈមកំពុងលេចឡើងថ្មីៗ ដោយស្របតាមមូលបទនៃកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានឆ្នាំ២០២២ ស្តីពី "*សាមគ្គីភាពដើម្បីសន្តិសុខប្រកបដោយភាពសុខដុម*"។

ថ្ងៃពុធ ០១កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២